Reçu le 4-11-51
INDOCHINE FRANÇAISE
RÉGIE DU DÉPÔT LÉGAL

# មិត្តសាលាបាលី

ទស្សនាវដ្ដីផ្សាយពុទ្ធសាសនា និង អក្សរសាស្ត្រខ្មែរ



ឆ្នាំទី ១ វិច្ឆិកា លេខ ១១

ព. ស. ២៤៩៣ — គ. ស. ១៩៥០

ទស្សនាវដ្ដីអនុមាសផ្សាយព្រះពុទ្ធសាសនានិងអក្សរសាស្ត្រខ្មែរ

បណ្ណាធិការ **ឈឹម - ក្រសេម**

សំណាក់ការ លេខ ៣៥ អា., វិថីឧកញ៉ាពេជ្រ ក្រុងភ្នំពេញ

## បញ្ជីរឿង


| | | ទំព័រ |
|---|---|---|
| វិចារណកថា | | ៤០១ |
| ប្រស្នាដើមកំណើតមនុស្ស | សុភមិត្ត | ៤០៣ |
| ប្រវត្តិលោកឧកញ៉ា នូ-កន | នុត - ពេញ | ៤២០ |
| ក្បួនមេកាព្យ (តមក) | ឧកញ៉ាសុត្តន្តប្រីជាឥន្ទ | ៤២៥ |
| ការសាងអាយតនៈ (តនឹងចប់) | តៃ - ជុន | ៤២៨ |
| បញ្ចតន្ត្រៈ (តមក) សេចក្តីប្រែរបស់ | ភិក្ខុប៉ាង - ខាត់ | ៤៣៣ |
| សេចក្តីថ្លែងការណ៍ | | ៤៣៩ |


---

| ដំឡៃជាវ | | |
|---|---|---|
| | ១ ឆ្នាំ | ៩៦,០០ |
| | ១ ឆមាស | ៤៨, ០០ |
| | ១ ត្រីមាស | ២៤, ០០ |
| | ១ ក្បាល | ៨, ០០ |

---


អ្នកអានទាំងឡាយ! សូមអញ្ជើញចុះឈ្មោះជាវ!

និងបបួលញាតិមិត្តជួយជាវ!

ជីវិតទស្សនាវដ្ដីសូមផ្ញើលើលោកអ្នក ។

# វិចារណកថា

ដើម្បីនឹងទទួលនូវសេចក្ដីសុខក្នុងសង្គម យើងតោងកាន់នូវបញ្ញ-សីលឲ្យជាប់ជានិច្ច មាននិស្ស័យជាអ្នកឲ្យ មានកាយនឹងវាចាស្រគត់ស្រគំទន់ភ្លន់ គឺថាធ្វើខ្លួនយើងឲ្យចុះសំរុងទៅតាមច្បាប់នៃសង្គម កុំឲ្យជាសត្រូវដល់ជនដទៃ ឬកុំឲ្យជនដទៃមកជាសត្រូវដល់យើងវិញ ។

តែសត្រូវដែលយើងត្រូវផ្ចាញ់ដើម្បីយកសុខនោះ នៅពុំទាន់អស់នៅឡើយទេ សត្រូវទី ២ គឺលោកដែលយើងឋិតនៅនេះឯង ព្រោះលោកនេះប្រកបដោយលក្ខណៈ ដែលផ្ទុយស្រឡះ ដែលប្រឆាំងនឹងសេចក្ដីត្រូវការរបស់យើង គឺតែងតែប្រែប្រួលទៅដោយឆាប់រហ័ស មិននៅក្រោមបង្គាប់អ្នកណា ជាហេតុនាំឲ្យយើងបានសេចក្ដីទុក្ខជាអនេក-បរិយាយ, កើតឡើងហើយ តែងប្រែប្រួលទៅ, រូបវិនាសបាត់ទៅតែដូច្នេះជានិច្ចកាល ។ វត្ថុណាដែលយើងចង់ឲ្យគង់នៅឋិតថេរដូចដើម វត្ថុនោះបេះតែពីផ្លាស់ប្ដូរសភាពជាធម្មតា ប្រាសឆ្ងាយពីយើងទៅ អន្តរធានសូន្យបាត់ទៅ ទុកយើងឲ្យនៅចម្បែកចម្បែងអាលោះអាល័យ ឬក៏យើងត្រូវឃ្លាតឆ្ងាយពីវត្ថុនោះទៅ ។

កាលបើលោកនេះ មិនលុះក្នុងអំណាចរបស់អ្នកណា មានធម្មតាតែងប្រែប្រួល វិនាសសាបសូន្យ គឺកើតឡើងហើយ តែងអន្តរធានបង់

ទៅវិញដូច្នេះ, យើងមិនអាចនឹងប្រែប្រួលសំរួលសភាពលោកឲ្យសមទៅតាមចិត្តរបស់យើងបានឡើយ គប្បីតែបណ្ដោយខ្លួនយើងទៅតាមលោក តាមច្បាប់របស់លោកវិញ បីដូចសត្វទន្សាយដែលគប្បីតែពួនក្នុងរូងរបស់ខ្លួនទើបសុខខ្លួន តែចេះចេញកាលហើយមុខជានឹងបានទៅជាចំណីនៃសត្វដទៃមិនខាន ។ តែតាមសង្កេតមក យើងមិនព្រមធ្វើបែបនោះសោះ ចង់តែប្រឆាំងនឹងលោកឲ្យបានតែរឿងទុក្ខលំបាក ។

ដូច្នេះ សត្រូវរបស់យើង គឺខ្លួនយើងនេះឯង ជាសត្រូវនៅជិតបង្កើយតែដូចជានៅឆ្ងាយ ពិបាកនឹងបង្ក្រាបឲ្យចាលចាញ់ពន់ពេក ព្រោះយើងមើលពុំឃើញជាក់ ដោយពុំស្គាល់ច្បាស់ថា តើខ្លួនយើងនេះជាអ្វី ដោយហេតុនោះ ទើបព្រះដ៏មានព្រះភាគទ្រង់ទូន្មានថា ការឈ្នះខ្លួននេះជាការឈ្នះដ៏ប្រសើរក្រៃលែង ។

សត្រូវនេះ នឹងផ្ចាញ់បាន ដោយការពិចារណារកដើមកំណើត រកគ្រឿងផ្សំ រកហេតុនឹងបច្ច័យនៃខ្លួននោះឲ្យឃើញតាមសេចក្ដីពិត ហើយបណ្ដោះបណ្ដាលចិត្តលែងឲ្យជាប់ជំពាក់នឹងខ្លួនជាសត្រូវនោះទៀត ។

ការបណ្ដោះបណ្ដាលចិត្ត យើងអាចនឹងសន្សំបានបន្តិចម្ដងៗ ដោយការមិនធ្វើខ្លួនឲ្យជាសត្រូវដល់អ្នកដទៃ - ដល់លោក គឺការកាន់បញ្ចសីលនោះឯង, តមក ត្រូវដោះការជាប់ជំពាក់នោះដោយចំរើនសមាធិ ។

ម្នាលអានន្ទ! អ្នកណាមួយ ទោះជាភិក្ខុក្ដី ជាភិក្ខុនីក្ដី ជាឧបាសកក្ដី ជាឧបាសិកាក្ដី ប្រតិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិដោយសេចក្ដីគោរពត្រង់ ប្រព្រឹត្តតាមធម៌, អ្នកនោះទើបឈ្មោះថាធ្វើសក្ការៈ គោរព រាប់អាន និងបូជា ចំពោះតថាគត ដោយការបូជាដ៏ប្រសើរបំផុត ។

មហាបរិនិព្វានសូត្រ មហា. ទីឃ.

# ប្រស្នាដើមកំណើតមនុស្ស

កាលពីក្នុងលេខមុនយើងបានឃើញមកហើយថា មនុស្សយើងដែលស្លាប់ទៅ តែងចាប់ជាតិជាថ្មីទៀត ព្រោះមានចិត្តជាប់ជំពាក់នឹងរាងកាយ ដែលជាគ្រឿងសំរាប់រះរាមស្វែងរកសេចក្ដីសប្បាយភ្លេតភ្លើនក្នុងលោក ក្នុងលេខនេះ យើងនឹងពិចារណាអំពីបដិបត្តិការនៃជាតិឲ្យល្អិតទៅទៀត ។

លោកនេះតែងប្រព្រឹត្តទៅតាមច្បាប់ហេតុផល គឺថា ហេតុមានទើបផលកើត នេះមាននោះក៏កើត ឬក៏គ្មានអ្វីនឹងកើតឡើងបានដោយមិនមានបច្ច័យនឹងអ្វីដែលមានមុនមកហើយនោះទេ គឺថាអ្វីនីមួយដែលមានដើមកំណើតមកហើយ នឹងបានជាបច្ច័យនាំឲ្យកើតអ្វីមួយតទៅទៀតពុំខាន ដូច្នេះពុំមានអ្វីដែលអាចទុកជាហេតុដើមបានឡើយ ការដែលយល់ថាមាន

ព្រះអាទិទេពបង្កើតមនុស្សសត្វនោះ ជាការយល់ដោយទ័លគំនិតទ័លប្រាជ្ញា ព្រោះបើនឹងសួរថាតើ ដោយមានអ្វីជាបច្ច័យ ទើបកើតព្រះអាទិទេព នឹងរកផ្លូវដោះសាពុំកើត ឯជាតិសោតនឹងអាចយល់បានដោយច្បាស់លាស់ដោយសារតែពន្លឺនៃធម៌ដែលជាបច្ច័យនឹងគ្នាប៉ុណ្ណោះ តាមភាសាធម៌លោកហៅថា បដិច្ចសមុប្បាទ ។

ក្នុងមហានិទានសូត្រ ទីឃនិកាយ ព្រះពុទ្ធជាម្ចាស់បានសម្តែងប្រាប់អានន្ទថា :

" តថាគតសម្តែងថា ជាតិមានភពជាបច្ច័យឲ្យកើត សេចក្តីនេះគួរយល់ដូច្នេះ អានន្ទចូរគិតមើល ថាបើគ្មានភពសំរាប់នរណាដោយប្រការឯណាទេ ក្នុងកាមលោកក្តី ក្នុងរូបលោកក្តីក្នុងអរូបលោកក្តី ក្នុងទីណាៗក្តី ជាបើភពផុតរលត់អស់ហើយតើជាតិនឹងកើតមានឬទេ ?

— ពុំកើតមានទេព្រះអង្គ

— ដូច្នេះ ភពជាបច្ច័យ ជាឱកាស ជាដើមកំណើតនៃជាតិ ជាតិកើតមានព្រោះភពជាបច្ច័យ " ។

បដិច្ចសមុប្បាទដែលជាច្បាប់គ្រប់គ្រងលោកមាន ១២ និទានដូចតទៅនេះ

— សង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ

— វិញ្ញាណកើតមាន ព្រោះសង្ខារជាបច្ច័យ

— នាមរូបកើតមាន ព្រោះវិញ្ញាណជាបច្ច័យ

- សឡាយតនៈកើតមាន ព្រោះនាមរូបជាបច្ច័យ
- ផស្សៈកើតមាន ព្រោះសឡាយតនៈជាបច្ច័យ
- វេទនាកើតមាន ព្រោះ ផស្សៈ ជាបច្ច័យ
- តណ្ហាកើតមាន ព្រោះ វេទនា ជាបច្ច័យ
- ឧបាទានកើតមាន ព្រោះ តណ្ហា ជាបច្ច័យ
- ភពកើតមាន ព្រោះ ឧបាទាន ជាបច្ច័យ
- ជាតិកើតមាន ព្រោះ ភព ជាបច្ច័យ
- ជរាមរណៈកើតមាន ព្រោះ ជាតិ ជាបច្ច័យ

ឯសេចក្ដីសោកស្ដាយ សេចក្ដីខ្សឹកខ្សួល សេចក្ដីលំបាកកាយ លំបាកចិត្ត និងសេចក្ដីចង្អៀតចង្អល់ចិត្ត ក៏កើតមានព្រមនឹងជាតិ ៗ

និទានធម៌មួយ ៗ នៃកងពោលគឺបដិច្ចសមុប្បាទនេះ ពុំមែនជាហេតុឲ្យកើតនូវនិទានដទៃទេ គឺថា អវិជ្ជា ពុំមែនជាហេតុឲ្យកើតវិញ្ញាណ វេទនាពុំមែនជាហេតុឲ្យកើតតណ្ហានោះទេ គេងយល់ថា ទីណាដែលមានតណ្ហា វេទនាក៏មានប្រាកដ ទីណាដែលមានវេទនា ទីនោះត្រូវតែមានវិញ្ញាណ បើមានវិញ្ញាណបណ្ដាលឲ្យមានតណ្ហាពេលណា អវិជ្ជាក៏មានក្នុងពេលនោះ ប្រព្រឹត្តទាក់ទងគ្នាដូច្នេះ ប្រៀបដូចជារលកដែលច្រានឲ្យរលកមួយទៀតកើតឡើង ឯរលកថ្មីនោះធ្វើឲ្យកើតរលកថ្មីមួយតទៅទៀត ជាលំដាប់ ៗ ទៅ ៗ

សូមលើកនិទានមួយ ៗ យកមកពិចារណា ៗ

## ១ ជរា – មរណៈ

ជរា-មរណៈ កើតមានព្រោះជាតិជាបច្ច័យ អត្តភាពរបស់យើងនេះ យើងអាចសង្កេតឃើញរៀងរាល់ថ្ងៃមកហើយ តែងប្រែប្រួលទ្រុឌទ្រោម ចាស់ជរាហើយស្លាប់បាត់ទៅ ទាំងនេះមកពីមានជាតិ ព្រោះតែកើតបាន ជាចាស់ជាស្លាប់ ៗ

## ២ – ជាតិ

ជាតិកើតមានព្រោះភពជាបច្ច័យ ជាតិក្នុងទីនេះ បានសេចក្តីថា ការកើត ការកើតដោយល្អ ការប្រសូត ការរស់នៅ ការប្រាកដ ការប្រាកដនៃខន្ធទាំង ៥ ការបរិបូណ៌នៃអាយតនៈ ១២ ៗ ជាតិនេះមិនអាចកើតចេញពីទទេទេ តែងអាស្រ័យដល់ភពសំរាប់អត្តភាពមនុស្ស ជាតិជាផលនៃកម្មដែលបានប្រព្រឹត្តកន្លងមកហើយ ព្រោះអត្តភាពមនុស្សពុំមែនអ្វីក្រៅអំពីសេចក្តីប្រាថ្នា សេចក្តីសង្ឃឹមសេចក្តីខ្វល់ខ្វាយជាដើមនោះទេ ប្រសិនបើក្នុងពេលស្លាប់ពុំមានអ្វីជាតួភពទេ ជាតិដែលនាំទៅកាន់មរណៈទៀតនោះ មិនអាចនឹងកើតឡើងបានឡើយ ជាតិបច្ចុប្បន្នគ្រាន់តែជាក្រសែថ្មីមួយបន្តពីជាតិដែលកន្លងមកហើយជាបន្ទាប់គ្នានោះ ៗ

ចុះភពនឹងជាតិខុសគ្នាដូចម្តេច? ភពបានដល់ផលគុប្បកើតចាក ហេតុធម្ម គឺកម្មភពដែលជាចេតនា ២៩ ដួង ភពមាន ២ យ៉ាងគឺ កម្មភព

និងឧបបត្តិភព ; ឧបបត្តិភពបានដល់ភពទាំង ៩ ក្នុងភូមិ ៣១ ពាក្យថាភពគឺកម្មដែលប្រព្រឹត្តទៅក្នុងភូមិ ៣១ ។ ចំណែកពាក្យថាជាតិ បានដល់បដិសន្ធិក្នុងភូមិ ៣១ គឺកម្មភពធ្វើឲ្យឧបបត្តិភពកើត ឧបបត្តិភពធ្វើឲ្យជាតិកើត ។ ដូច្នេះភពបានដល់កុសលអកុសលកម្ម និងផលនៃកុសលអកុសល ឯជាតិគឺការបដិសន្ធិក្នុងភពផ្សេងៗ ឧបមាដូចដើមឈើដែលមានផ្លែផ្កា ដើមឈើជាឧបបត្តិភព ពូជនៃឈើនោះជាកម្មភព ឯការមានផ្លែផ្កាគឺជាតិ ។

## ៣ – ភព

ភពកើតមានព្រោះឧបាទានជាបច្ច័យ ភវៈបានសេចក្តីថាធម្មជាតិដែលនាំឲ្យកើតវិបាកនិងកដត្តារូប បានដល់កម្មភពដ៏ជាចេតនានៃកុសលនិងអកុសល ន័យមួយវិញទៀត គឺធម្មជាតិដែលធ្វើឲ្យ កាមភព រូបភព អរូបភពកើត បានដល់ឧបបត្តិភពដ៏ជាបដិសន្ធិវិញ្ញាណព្រមនិងរូប ។ ការរស់នៅរបស់យើងសព្វថ្ងៃនេះជាការជាប់ជំពាក់គតសោយ ដើម្បីបង្កើននូវវត្ថុដែលយើងត្រូវការប្រាថ្នាចង់បានឲ្យមកនៅក្នុងកណ្តាប់ដៃរបស់យើង ហើយបំពេញកិច្ចការទៅតាមការជាប់ជំពាក់នោះ សកម្មភាពរបស់យើងប្រព្រឹត្តទៅតាមការជាប់ជំពាក់នោះ ឧបមាដូចយើងចង់បានផ្លែក្រូច យើងតោងស្ទុះស្វែងឲ្យបានដល់ផ្លែក្រូច ហើយទាញបេះកាន់ជាប់នឹងដៃមក ទើបផ្លែក្រូចនោះបានមកជារបស់យើង ដូច្នេះ ភពនឹងកើតមាន ព្រោះសេចក្តីជាប់ជំពាក់គឺឧបាទានរបស់យើង និងសេចក្តីប្រឹងប្រែងដើម្បីសំរេចនូវឧបាទាននោះ ជាបច្ច័យ ។

## ៤— ឧបាទាន

ឧបាទានកើតមាន ព្រោះតណ្ហាជាបច្ច័យ ឧបាទានបានដល់សភាពដែលតោងអារម្មណ៍ហើយចាប់ទុក ផ្លែក្រូចដែលយើងធ្វើកិច្ចប្រកាន់តោងចាប់យកមកនោះ ព្រោះតែយើងចង់បាន បើមិនចង់បាន យើងក៏ឥតព្រះរាមទឹងប្រកាន់តោងទឹងជាប់ជំពាក់ចិត្តទេ ព្រោះយើងចង់ចេះទើបយើងខំហាត់សង្កាត់រៀនសូត្រ ជាប់ជំពាក់ក្នុងការរៀនសូត្រ ដូច្នេះឧបាទានកើតមាន ព្រោះតណ្ហាជាបច្ច័យ ។ ឯតណ្ហានឹងឧបាទានបានដល់ការលោភដូចគ្នា ខុសគ្នាត្រង់កំឡាំង គឺសេចក្ដីចង់បានមានកំឡាំងខ្សោយឈ្មោះថាតណ្ហា បើមានកំឡាំងខ្លាំងឈ្មោះថាឧបាទាន ; តណ្ហាមានទុក្ខនៃការស្វែងរកទ្រព្យសម្បត្តិជាមូល ឯឧបាទានមានទុក្ខនៃការរក្សាទ្រព្យជាមូល ។

## ៥— តណ្ហា

តណ្ហាកើតមាន ព្រោះវេទនាជាបច្ច័យ តណ្ហាគឺសភាពដែលចង់បាន ដែលស្រេកឃ្លានអារម្មណ៍ យើងបានឃើញមកហើយថា នឹងទុកជាសត្វជាបុគ្គលបាន លុះត្រាតែអារម្មណ៍ផ្សំនឹងចិត្ត ដូច្នេះតណ្ហានេះអាចនិយាយសេចក្ដីបានថាការចង់រស់នោះឯង ជាហេតុនាំឲ្យយើងប្រព្រឹត្តកម្មចំសំកប់ជីវិតជានិច្ច ឲ្យស្វះស្វែងរកអាហារចំអែតពោះ ឲ្យបំពេញនូវកិច្ចផ្សេង ៗ ដើម្បីញ៉ាំងជីវិតឲ្យបានស្រួលតាមសេចក្ដីគាប់ចិត្ត តែថានឹងចង់

បានអ្វីៗ ឬនឹងស្រេកឃ្លាននូវអារម្មណ៍ទៅកើត លុះត្រាតែភ្ជាប់បានក្រេបរសជាតិអារម្មណ៍នោះមករួចហើយ ដឹងឆ្ងាញ់ពិសាទើបចង់បានទៀត ព្រោះហេតុនោះ តណ្ហាកើតមានព្រោះវេទនាជាបច្ច័យ ។

## ៦ – វេទនា

វេទនា កើតមានព្រោះផស្សៈជាបច្ច័យ វេទនាគឺធម្មជាតិដែលសោយនូវអារម្មណ៍ យើងនឹងអាចដឹងបានថាចំរៀងនោះពិរោះឬមិនពិរោះ លុះត្រាតែសំឡេងនៃចំរៀងនោះមកប៉ះនឹងត្រចៀកយើង បើមិនប៉ះទេ យើងមិនអាចដឹងបានថាមានចំរៀងផង កាលបានប៉ះសំឡេងនៃចំរៀងនោះហើយ យើងអាចដឹងបានថាពិរោះឬមិនពិរោះ បើពិរោះ យើងចង់ស្តាប់តទៅទៀត ការចង់នេះឯងនាំឲ្យយើងជាប់ជំពាក់នឹងជាតិ ដូច្នេះ វេទនាកើតមានព្រោះផស្សៈជាបច្ច័យ ។

## ៧ – ផស្សៈ

ផស្សៈកើតមានព្រោះសឡាយតនៈជាបច្ច័យ ផស្សៈគឺធម្មជាតិដែលប៉ះពាល់អារម្មណ៍ គឺការភ្ជាប់អារម្មណ៍នឹងអាយតនៈឯណាមួយរបស់យើង បើយើងខ្វាក់ភ្នែក យើងមើលអ្វីមិនឃើញទេ ឯផស្សៈក៏មិនកើតមាន ឬក៏ត្រចៀកយើងឥតថ្លង់ទេ តែយើងកំពុងជក់អានសៀវភៅ សូម្បីគេនិយាយខ្លាំងនៅផ្លូវ ក៏ត្រចៀកយើងមិនអាចឮនូវសូរគេនិយាយគ្នានោះបាន ព្រោះអាយតនៈរបស់យើងនេះមិនទទួលនូវអារម្មណ៍នោះ ដូច្នេះ ផស្សៈកើតមានព្រោះអាយតនៈជាបច្ច័យ ។

## ៨ – សឡាយតន

សឡាយតនៈកើតមានព្រោះនាមរូបជាបច្ច័យ សឡាយតនៈបាន ដល់អាយតនៈទាំង៦ គឺចក្ខុ សោតៈ ឃានៈជិវ្ហា កាយនិងមនោ; អាយតនៈ ទាំងនេះកើតមានព្រោះនាមរូបកើតហើយ បីដូចដើមមែកស្លឹកឈើវមែង បែកចេញពីពូជ ដូច្នេះសឡាយតនៈកើតមានព្រោះនាមរូបជាបច្ច័យ ។

## ៩ – នាមរូប

នាមរូបកើតមានព្រោះវិញ្ញាណជាបច្ច័យ នាមគឺសភាពដែលខុនទៅ រកអារម្មណ៍ រូបគឺសភាពដែលបែកធ្លាយ ឈ្មោះសត្វដែលយើងមិនដែល ស្គាល់ តើនឹងបានសេចក្ដីដូចម្ដេចដល់យើង? ឯរូបកាយសណ្ឋានរៃសត្វ នោះក៏នឹងជាអ្វីដល់យើងដែរ, នឹងប្រាកដច្បាស់ដល់យើង លុះត្រាតែ យើងដឹងយើងស្គាល់ នាមរូបក៏ទីនេះបានដល់រូបបរមត្ថ និងចេតសិក- បរមត្ថ បើគ្មានចិត្តគឺវិញ្ញាណទេ ចេតសិកនិងរូបនោះកើតឡើងពុំបាន ដូច្នេះ នាមរូបកើតមានព្រោះវិញ្ញាណជាបច្ច័យ ។

## ១០ – វិញ្ញាណ

វិញ្ញាណកើតមាន ព្រោះសំខារជាបច្ច័យ វិញ្ញាណគឺការដឹងនូវ អារម្មណ៍ បានដល់បដិសន្ធិវិញ្ញាណនិងបវត្តិវិញ្ញាណ យើងនឹងអាចដឹង បានថាសត្វនាជាសត្វបែបណានោះ ព្រោះបានផ្សំបានផ្ដិតយកលក្ខណៈ នៃធានោះមកហើយ ថាជាសត្វមានខ្លួនតូចល្មម មានជើងបួនព្រម

ដោយគ្រប់គប់បញ្ចេញបញ្ចូលបានតាមចិត្ត មានមុខត្រចៀកខ្វីជាដើម បើគ្មានការតាក់តែងផ្សំលក្ខណៈទាំងនោះមកទេ យើងមិនអាចដឹងថាជាគ្នាបានឡើយ ដូច្នេះ វិញ្ញាណកើតមានព្រោះសំខារជាបច្ច័យ ។

## ១១ – សង្ខារ

សំខារកើតមានព្រោះអវិជ្ជាជាបច្ច័យ សង្ខារ គឺធម្មជាតិដែលតាក់តែងសង្ខតធម្ម ឬ នាមរូប ឬជីវិតឲ្យកើតឡើង ឧបមាដូចការតាក់តែងសង់ផ្ទះ ការសង់នេះព្រោះការចង់នៅ បានជាចង់នៅព្រោះយល់ថាផ្ទះនោះនឹងបិតបើរបរិភោគ អាចនឹងការពារនូវភ្លៀងផ្គរនឹងភ័យទាំងឡាយបានជានិច្ច តាមពិតផ្ទះនោះតែងប្រែប្រួលវិនាសទ្រុឌទ្រោមទៅជាធម្មតា តែយើងយល់ខុសពីនោះទៅវិញ ព្រោះយើងមិនដឹងនូវលក្ខណៈនៃផ្ទះនោះ ដូច្នេះ សង្ខារកើតមានព្រោះអវិជ្ជាជាបច្ច័យ ។

## ១២ – អវិជ្ជា

អវិជ្ជាគឺការមិនដឹងនូវលក្ខណៈនៃសភាវទាំងឡាយ នូវអរិយសច្ច អវិជ្ជាជាប្រការទី ១ នៃបដិច្ចសមុប្បាទ ជាហេតុឲ្យមានជាតិ ព្រោះកាលបើយើងដឹងថាជាតិនេះជាគំនរនៃភ្លើងទុក្ខហើយ យើងក៏នឹងមិនពេញចិត្ត មិនជាប់ចិត្តនឹងការកើតទៀតទេ ចុះមានអ្វីមុនអវិជ្ជានេះ? អវិជ្ជាប្រៀបដូចភ្លើង ភ្លើងតែងមាន តែងតែមានមកជានិច្ច តែភ្លើងនឹងប្រាកដឡើងបាន លុះតែប្រកបដោយលក្ខណៈសម្បត្តិគ្រប់ព្រម គឺតោងមានឈើស្ងួត

មានការកួតនៃឈើស្ងួតនោះ ទើបចេញភ្លើង សេចក្តីនេះមានឧបមាយ៉ាង ណាមិញ អវិជ្ជាក៏មានឧបមេយ្យយ៉ាងនោះដែរ ។

ដូច្នេះ ដោយអាស្រ័យការយល់ខុសវង្វេងមិនស្គាល់នូវសភាវៈធម៌ ដោយច្បាស់លាស់ថាមានលក្ខណៈជា អនិច្ចៈ ទុក្ខៈ អនត្តៈ បែរយល់ថា ឋិតថេរ ថាសុខថាជារបស់ខ្លួន សត្វមានចេតនាទឹងតាក់តែងនូវបដិសន្ធិ (វិញ្ញាណ) ឲ្យកើតនូវចេតសិកនិងរូប (នាមរូប) ឡើង ប្រកបព្រមដោយ អាយតនៈ ដើម្បីត្រេកត្រងសោយនូវអារម្មណ៍ (វេទនា) ដោយអាស្រ័យ ការប៉ះពាល់ (ផស្សៈ) នូវអារម្មណ៍ លុះបានត្រេកអរសជាតិអារម្មណ៍នោះ ក៏កើតសេចក្តីពេញចិត្ត (តណ្ហា) ចង់បានអារម្មណ៍នោះតទៅទៀត ។

តណ្ហាគឺការពេញចិត្តក្នុង រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ធម្មៈ ជាគ្រឿងញាក់ចិត្តឲ្យសព្វក្នុងអារម្មណ៍ទាំង ៦ នោះ ព្រោះវេទនាការ សោយអារម្មណ៍ជាបច្ច័យតាមសម្ផស្ស ដែលជាដែនកើត ជាទីប្រជុំនៃធម៌ ៣ ប្រការតាមទ្វារនោះៗ កាលចក្ខុនិងរូបប៉ះប្រទះគ្នា ចក្ខុវិញ្ញាណក៏កើត ចិត្តបានដឹងវិសេសក្នុងចក្ខុ ដោយអាស្រ័យចក្ខុ ការប្រជុំនៃធម៌ ៣ ប្រការ គឺចក្ខុ ១ រូប ១ និងចក្ខុវិញ្ញាណ ១ ឈ្មោះថាសម្ផស្ស លុះសម្ផស្សកើតហើយ សត្វក៏បានសោយវេទនា ជាសុខខ្លះ ជាទុក្ខខ្លះ ជាឧបេក្ខាខ្លះ តែទីនេះ សំដៅយកសុខវេទនា ព្រោះជាឧបនិស្សយបច្ច័យ ចំណែកទុក្ខវេទនាជា គ្រឿងក្តៅនាំឲ្យរកសុខវេទនា ពេញចិត្តនឹងវេទនានោះ ខំប្រឹងប្រែង

ឧបត្ថម្ភគាំទ្រនូវអារម្មណ៍ មាន រូប សំឡេង ក្លិន រស របស់ខ្លួននិងអ្នកដទៃ ជាបច្ច័យឲ្យកើតឧបាទានចាប់ផ្ដក់យកភពសំរាប់ឲ្យកើតជាតិ ដើម្បីជញ្ជៀបរសជាតិនៃអារម្មណ៍នោះតទៅទៀត បានក្រេបហើយចង់ក្រេបទៀត តណ្ហាបេះតែខ្លាំងក្លាឡើងមិនបេះអស់ហើយមានកិរិយាមិនឆ្អែតនូវអារម្មណ៍ជាផល ព្រោះហេតុនោះ ទើបមានជាតិជាប់ៗ គ្នាមិនផុត ។

បដិច្ចសមុប្បាទធម៌ ជាធម៌អាស្រ័យគ្នានិងគ្នាលះបង់គ្នាមិនរួច កើតអាស្រ័យដោយជាតិ រលត់ទៅជាមួយនឹងជាតិ លោកចែកជា ៣ កាល ដូចមានក្នុងតារាងខាងក្រោមនេះ ។

| | អតីត | បច្ចុប្បន្ន | អនាគត |
|---|---|---|---|
| កម្មភព | ក<br>១) អវិជ្ជា<br>២) សង្ខារ | ខ<br>៨– តណ្ហា<br>៩– ឧបាទាន<br>. . . . . . . . . .<br>. . . . . ១០– ភព | |
| ឧបបត្តិភព | | គ<br>៣ – វិញ្ញាណ<br>៤ – នាមរូប<br>៥ – សឡាយតនៈ<br>៦ – ផស្សៈ<br>៧ – វេទនា | ឃ<br>១១– ជាតិ<br>១២– ជរា-មរណៈ |

លោកចែកជាហេតុនិងជាផលឲ្យឃើញដូច្នេះ  កម្មភពជាអតីតហេតុ  ឧបបត្តិភពជាបច្ចុប្បន្នផល  កម្មភពជាបច្ចុប្បន្នហេតុ  ឧបបត្តិភពជាអនាគតផល ។

| អតីតហេតុ | បច្ចុប្បន្នផល | បច្ចុប្បន្នហេតុ | អនាគតផល |
|---|---|---|---|
| ១– អវិជ្ជា | ១– វិញ្ញាណ | ១– តណ្ហា | ១– វិញ្ញាណ |
| ២– សង្ខារ | ២– នាមរូប | ២– ឧបាទាន | ២– នាមរូប |
| ៣– តណ្ហា | ៣– សឡាយតនៈ | ៣– ភព | ៣– សឡាយតនៈ |
| ៤– ឧបាទាន | ៤– ផស្សៈ | ៤– អវិជ្ជា | ៤– ផស្សៈ |
| ៥– ភព | ៥– វេទនា | ៥– សង្ខារ | ៥– វេទនា |

ឯសេចក្តីថា  ជាតិ ១ ជរា ១ មរណៈ ១ ទាំង ៣ នេះមិនផ្សេងគ្នាចាកបច្ចុប្បន្នផលប្រាំ ៗ នោះទេ,  កាលបច្ចុប្បន្នផលកើតឡើងហើយក៏ហៅថាជាតិ  លុះគ្រាំគ្រាទៅហៅថាជរា  លុះបែកធ្លាយទៅហៅថាមរណៈ  ដូច្នេះជាតិ  គឺការកើតនៃ  វិញ្ញាណ  នាមរូប  សឡាយតនៈ  ផស្សៈ  និងវេទនា ។

ចំណែកការជាប់ទាក់ទងគ្នាពីជាតិមួយទៅជាតិមួយនោះ  ប្រព្រឹត្តទៅដូច្នោះ  ដោយអំណាចអវិជ្ជា  សង្ខារជាអតីតហេតុតាក់តែងជាតិឲ្យកើត (វិញ្ញាណ)  វេទនាគឺការសោយអារម្មណ៍ពេញចិត្តក្នុងបច្ចុប្បន្នកាលឲ្យកើតតណ្ហាប្រាថ្នានូវអារម្មណ៍នោះ  ប្តក់តោងនូវភព  ភពឲ្យ

កើតជាតិតៗគ្នាទៅទៀត ៗ ដូច្នេះ កាលអារម្មណ៍ខាងក្រៅចូលទៅត្រង់តែងប្រែចិត្ត កើតជាអារម្មណ៍ខាងក្នុងឲ្យចិត្តសំគាល់ខុស (សញ្ញា) ថាជាសុខ ថានៅឋិតថេរ ថាជារបស់ខ្លួនព្រោះមោហៈ (អវិជ្ជា) បិទបាំងមិនឲ្យឃើញច្បាស់តាមសភាពពិត កើតពេញចិត្ត (លោភ) ចំពោះអារម្មណ៍នោះ ត្រូវការនូវអារម្មណ៍នោះទៀត (តណ្ហា) ខំឧបត្ថម្ភគាំទ្រឲ្យនៅឋិតថេរខ្ជាប់ខ្ជួន (ឧបាទាន) បើខុសបំណងក៏កើតប្រទូសរ៉ាយ (ទោស) បែរកេឲ្យសមបំណងឡើង សំឡឹងរកទីឲ្យកើតនូវអារម្មណ៍ជាទីពេញចិត្ត (ភព) ខ្នះខ្នែងប្រឹងប្រែងដោយកាយខ្លះដោយវាចាខ្លះ ដោយចិត្តខ្លះ (កម្ម) ហើយចូលទៅកាន់ទីនោះកន្លែងនោះ (ជាតិ) សំគាល់ខុស (អវិជ្ជា) ប្រាថ្នាចង់បានតទៅទៀត (តណ្ហា) វិលចុះវិលឡើងឥតស្រាក អារម្មណ៍ខាងក្នុងរលត់ផុតពេលណាក៏ពុំអាចដឹងបាន ជាតិនេះតែកើតរលត់ៗ ជាប់តៗគ្នា (សន្តតិ) ជាលំដាប់ឥតអាក់ ៗ

បើនឹងប្រើគ្រឿងប្រៀបធៀបក៏បានដល់ការ ឃើញក្រូចពោធិ៍សាត់ដឹងថាក្រូចនោះគួរដល់ការបរិភោគ កើតចង់បានក្រូចមកជារបស់ខ្លួន ខំប្រឹងប្រែងលុះត្រាតែបានមក លុះបានបរិភោគនូវក្រូចនោះហើយ ក៏ដឹងរសជាតិឆ្ងាញ់ពិសា កើតចង់បានក្រូចមកបរិភោគទៀត លុះបានហើយ ក៏ចង់តទៅទៀត មិនចេះអស់ មិនចេះហើយ ៗ ចិត្តដែលប្រែប្រួលទៅកាន់ក្រូចជាកិលេស, ការខ្វល់ខ្វាយស្វែងរកក្រូចឲ្យបានមក

ជាកម្ម, លុះបានបរិភោគនូវក្រូចនោះហើយដឹងរសជាតិឆ្ងាញ់ពីសាជាវិបាក; វិបាកគឺការឆ្ងាញ់ពីសានេះធ្វើចិត្តឲ្យស្រេកឃ្លានចំពោះក្រូចតទៅទៀត ក៏ក្លាយជាកិលេស, កិលេសជាកម្មតទៅទៀត ហើយជាវដ្ដៈវិលចុះឡើងឥតស្រាកស្រាន្ត ។

យើងនឹងល្បងពិចារណា ពីការបែកធ្លាយ នូវខន្ធទាំង ៥ ដែលគេសន្មតថាស្លាប់តទៅទៀត: មនុស្សសត្វទាំងឡាយមានធាតុ ៤ ជាគ្រឿងឧបត្ថម្ភគាំទ្រជានិច្ច គឺ កម្ម ចិត្ត អាហារ និងឧតុ ។ ពេលណាឈើទាំងចិត្ត អាហារនិងឧតុមានកំលាំងខ្សោយចុះ មិនអាចនឹងទ្រទ្រង់នូវធាតុដែលកើតពីកម្មបាន កម្មនឹងប្រព្រឹត្តទៅពុំបាន, ពេលនោះអាយតនទាំងឡាយក៏រលត់សាបសូន្យបង់, ពេលនោះ កម្មឬកម្មនិមិត្តឬគតិនិមិត្តក៏ប្រាកដដល់ចិត្ត, តែចិត្តមានកំលាំងខ្សោយចុះ វិថីចិត្តទាំង ១៧ ខណៈមិនអាចប្រព្រឹត្តជាប់តៗគ្នាបាន ព្រោះគ្មានអ្វីចូលទៅកាន់ក្រសែ អវិជ្ជានាំបំភាន់ឲ្យយល់សេចក្ដីសុខក្នុងជាតិ តណ្ហានាំឲ្យខ្វល់ខ្វាយ រកការកើតទៀត វិថីចិត្តប្រព្រឹត្តតទៅមិនដាច់ក្នុងភពថ្មី, ជាតិក៏ប្រាកដកើតឡើង ។

កើតប្រស្នាថ្មីឡើងថា ចុះអ្វីទៅកើតទៀត? ខន្ធទាំង៥ គឺ រូប វេទនា សញ្ញា សំខារ និងវិញ្ញាណ បែកធ្លាយវិនាសបង់បាត់ក្នុងពេលស្លាប់ ពុំឃើញមានសល់អ្វីទេ តាមពិតនោះ ដូចបានដឹងមកហើយមរណជា បញ្ញត្តិធម៌ នាមរូបតែងកើតរលត់ៗ ទៅតាមសន្តតិបីដូចក្រសែទឹកដែល

ហួរទៅជានិច្ច, ដែលយើងសន្មតថាស្លាប់នោះ គឺគ្រាន់តែជាក្រសែចិត្តដែលប្រព្រឹត្តៗ ពីខន្ធចាស់ផ្លាស់ចូលកាន់ខន្ធថ្មីដោយអំណាចសន្តតិប៉ុណ្ណោះ ដូចគ្នានឹងបច្ចុប្បន្នជាតិនេះឯង ឧបមាដូចសំឡេងដែលរត់ចូលក្នុងវិទ្យុដូច្នោះ សំឡេងនៃអ្នកនិយាយចេញផុតពីមាត់អ្នកនោះហើយ កើតជាកំឡាំងរត់ស្ទុះចូលក្នុងគ្រឿងស្រូប ប្រាកដចេញពីវិទ្យុដែលចាប់សំឡេងនោះលាន់ឮឡើង បើមានគ្រឿងស្រូបថ្មីទៀត សំឡេងវិទ្យុក៏ស្ទុះចូលក្នុងគ្រឿងស្រូបថ្មីនោះ ទៅប្រាកដក្នុងវិទ្យុថ្មីមួយទៀត បើបេះតែមានគ្រឿងស្រូបនឹងវិទ្យុសំកប់ទទួលដកបណា សំឡេងនោះនៅតែលាន់ឮដកបនោះដែរ ៗ

ឯបុណ្យនឹងបាបដែលបានសន្សំហើយ រមែងរលត់ទៅវិញជាធម្មតាក៏មែន តែមិនបានរលត់ទៅទទេៗឡើយ នៅសល់កំលាំងគឺផល ឬវិបាក ដូចកំលាំងរលកនៃសំឡេងអ្នកនិយាយខាងលើនោះ, សន្តតិនៃចិត្តរមែងប្រព្រឹត្តទៅមួយអន្លើ ដោយកំលាំងនោះបីដូចស្រមោលដែលជាប់តាមប្រាណ កំលាំងផលនៃកម្ម គឺបុណ្យនឹងបាបដែលជិតជាមតាមចិត្តនោះ ហៅថា និស្ស័យ ឬវាសនា ៗ វិធីដែលជិតជាមនោះដូច្នេះ :

១) ចេតនាសមគ្គី – ពេលដែលធ្វើបុណ្យនឹងបាប គោងបរិបូណ៌ដោយចេតនាជាមុន ៗ

២) កម្មសមគ្គី – អាស្រ័យចេតនាបានធ្វើបុណ្យឬធ្វើបាបទៅហើយ កម្មល្អឬអាក្រក់ក៏ប្រាកដឡើង ៗ

៣ ) ឧបដ្ឋានសមង្គី – ពេលជិតធ្លាយខន្ធ និមិត្តគឺកម្ម, កម្មនិមិត្ត និងគតិនិមិត្ត រមែងប្រាកដឡើង ។

៤ ) វិបាកសមង្គី – ក្រោយដែលឧបដ្ឋានសមង្គីរលត់ទៅកុសល អកុសលដែលបានធ្វើទុកនោះឲ្យផលក្នុងភពថ្មីភ្លាម ; ឯវិញ្ញាណ ផស្សៈ វេទនា អាស្រ័យបច្ច័យហើយក៏កើតតាមៗគ្នាឡើងសោយសុខ សោយទុក្ខជាលំដាប់ទៅ ។

សរុបសេចក្ដីទៅ យើងបានពិចារណាឃើញថាជាតិកើតឡើង ព្រោះបដិច្ចសមុប្បាទធម៌ទាំង ១២ ប្រការ ដែលអាស្រ័យគ្នាទៅវិញទៅមក ជាហេតុ ជាផលក្នុងកាលទាំង ៣ គឺអតីត បច្ចុប្បន្ន អនាគត ជាប់តៗគ្នាមិនដាច់ដោយអំណាចសន្តតិបុកម្ម, ថាមពល នៃកម្មនេះប្រាកដជាឧប្បាទធម្ម គឺជាតិមានអវិជ្ជាជាមូល មានតណ្ហា ជាគ្រឿងទ្រទ្រង់ ។ ដែលនឹងហៅថាសត្វ ថាបុគ្គលបាន លុះត្រាតែអារម្មណ៍ទៅផ្សំជាមួយនឹងចិត្ត, ឯចិត្តនេះតែងប្រព្រឹត្តក្នុង ៣ ខណៈ គឺឧប្បាទៈការកើតឡើង ឋីតិការឋិតនៅ ភង្គៈការរលត់ទៅវិញជានិច្ច បានសេចក្ដីថាការស្លាប់កើត - កើតស្លាប់ មានរាល់ខណៈនៃពេលដែលកំពុងរស់នៅ, ពាក្យថា "មរណៈ" គ្រាន់តែជាបញ្ញត្តិធម៌ប៉ុណ្ណោះ ។ អារម្មណ៍មានពីរយ៉ាង គឺអារម្មណ៍ខាងក្រៅ នឹងអារម្មណ៍ខាងក្នុង ។ អារម្មណ៍ខាងក្នុងនេះឯង នាំឲ្យកើតសញ្ញាការសំគាល់ឃើញថាអារម្មណ៍ជារបស់ខ្លួនជាសភាវៈនៅ

ឋិតថេរជានិច្ច, លុះអារម្មណ៍នោះរលត់បាត់ទៅយើងជាបុថុជ្ជនក៏ពុំអាចនឹងដឹងបាន, ឯចិត្តសោតក៏ស្ទុះទៅកាន់អារម្មណ៍ថ្មីទៅទៀតទៅហើយ, ប្រតិបត្តិការនៃជាតិព្រមទាំងសកម្មភាព ធាតុកម្ម បដិកិរិយា ជាអនេកនៃជាតិនេះមានសភាពដូចបានពោលមកហើយ ។

សូមជំរាបអ្នកអានឲ្យបានជ្រាបថា រឿងជាតិនេះជាប្រស្នាល្អិតល្អន់ជ្រាលជ្រៅពន់ពេក មិនអាចនឹងចាក់ធ្លុះបានដោយងាយៗឡើយ ឯសេចក្តីដែលបានពណ៌នាខាងលើនេះ ពុំមែនជាការដោះស្រាយនូវប្រស្នាស្មុគ្រស្មាញនេះឲ្យអស់ជើងទេ គ្រាន់តែបានជាលំនាំនៃការចោទប្រស្នា ហើយលើកគោលសំខាន់ៗដែលគប្បីពិចារណា មកចុះទុកតែប៉ុណ្ណោះ ។

សុភមិត្ត

---

“ម្នាលភិក្ខុផងទាំងឡាយ! ភិក្ខុ ដែលគ្រាន់តែមានសីលបរិសុទ្ធជាដើម ឬដែលគ្រាន់តែបានប្រទះនូវអនាគាមិសុខប៉ុណ្ណោះ មិនត្រូវប្រកាន់ស្ងួតគំនិតថា **ភារទុក្ខរបស់អាត្មាអញនៅសល់បន្តិចបន្តួច** ដូច្នេះទេ គឺថា បើមិនទាន់អស់អាសវៈនៅឡើយ កុំអាលសង្ឃឹមញញឹមគក់ក្តៅថា **អាត្មាអញបានសុខហើយ** ដូច្នេះឡើយ” ។

(ធម្មបទដ្ឋកថា)

# អក្សរសាស្ត្រជាពន្លឺជាតិ ជាគោលចារិកជាតិ
# អក្សរសាស្ត្ររលត់ ជាតិរលត់ ។

## ប្រវត្តិលោកឧកញ៉ា នូ-កាន

លោក នូ-កន មាតាឈ្មោះ អ៊ុក បិតាឈ្មោះ នូ កើតនៅឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ ក្នុងឆ្នាំ ១៨៧៤ ។

កាលអាយុ ៩ ឆ្នាំបានចូលទៅសិក្សារៀនអក្សរខ្មែរ ក្នុងសំណាក់លោកគ្រូ អ៊ិន ជាចៅអធិការវត្តអង្គតាគតឃុំដដែល ។ ដល់អាយុ ១៤ ឆ្នាំ បួសបព្វជ្ជាជាសាមណេរ ក្នុងសំណាក់លោកគ្រូចៅអធិការវត្តដដែល បានមួយវស្សាក៏សឹកទៅកាន់ភេទឃរាវាស ។ អាយុ ១៧ ឆ្នាំ បានចូលទៅធ្វើរាជការជាស្មៀន លោកចៅហ្វាយខេត្តទ្រាំង ។ ដាក់មុខក្រសួងឲ្យដើរទារពន្ធថ្ងៃរាជការខ្មែរ ជំរៀត ចិនយួន ក្នុងខេត្តដដែលនេះ, តាំងពីឆ្នាំ ១៨៩១-៩២-៩៣ ដល់ឆ្នាំ ១៨៩៤ បានទៅធ្វើរាជការ ក្នុងក្រុមព្រះអាល័ក្សក្នុងរជ្ជកាល ព្រះបាទសម្ដេចព្រះនរោត្តម ជាម្ចាស់ជីវិតលើត្បូង ។ ទ្រង់ក៏ផ្លាស់ជំណែងឲ្យធ្វើខាងក្រុមសុរិយោដីវិញ, អ្នកឧកញ៉ាពិភក្តិទេព្វរាជ (ម៉ម) ជាចាងហ្វាង តាំងឲ្យមានគោរម្យងាររជាម៉ឺនភក្តីអក្សរ ។ លោកចាងហ្វាងបានចាត់ឲ្យចេញដើរទៅទារពន្ធថ្ងៃរាជការខ្មែរ ខេត្តលើកដែក ។ ដល់ថ្ងៃ ១២ ខែធ្នូឆ្នាំ ១៨៩៥

រាជការបានចាត់ឲ្យទៅធ្វើរាជការនៅមន្ទីរ ប៉ុយរ៉ូឃ្លាំងប្រាក់ជាទីនិគិតគំរប់ ៥ ឆ្នាំ ទើបបានទទួលការតាំងស៊ប់ជាអ្នករាជការមានក្របខណ្ឌពេញទី ។ ថ្ងៃ ១ ខែឧសភាឆ្នាំ ១៩០២ បានចូលទៅប្រឡងអក្សរខ្មែរ បានសញ្ញាប័ត្រជាប់លេខ ១ ។ ថ្ងៃ ៣ ខែឧសភាឆ្នាំដដែល រាជការប្រូតិកតូរ៉ាត់តាំងឲ្យធ្វើបាឡាត់ខែត្រកំពង់សៀម ។ ដល់ឆ្នាំ ១៩០៣ រាជការក៏តាំងឲ្យធ្វើជាចៅហ្វាយខែត្រ ជំនួសចៅហ្វាយខែត្រកំពង់សៀម ៦ ខែ ថែមទាំងតាំងឲ្យធ្វើជាគ្រូបង្រៀនច្បាប់ នឹងទំនៀមទម្លាប់ខ្មែរ ក្នុងសាលាខែត្រកំពង់សៀម ។ ដល់ថ្ងៃ ៤ ខែឧសភា ឆ្នាំ ១៩០៨, រាជការចាត់ឲ្យទៅប្រទេសបារាំងសែស ដើម្បីពិនិត្យមើលកិច្ចការរាជការផ្សេងៗរបស់មហាប្រទេស អស់កាល ៩ ខែទើបត្រឡប់មកស្រុកខ្មែរវិញ ។

លំដាប់បន្ទាប់តៗ ពីនោះមក, រាជការបានតាំងនិងផ្លាស់ប្ដូរលោកទៅក្នុងតំណែងផ្សេងៗ ដូចខាងក្រោមនេះ

- ចៅហ្វាយខែត្រពញាឮ (១៦-៦-១៩០៩)
- ចៅហ្វាយខែត្រស្ទឹងត្រង់ (១១-១១-១៩០៩)
- ឧកញ៉ាសភាមន្ត្រីចៅក្រមសាលាឧទ្ធរណ៍ទី ១ (២០-២-១២)
- ឧកញ៉ាពិភក្តិវិនិច្ឆ័យចាងហ្វាងសាលាលូកឃុន (១១-៤-១២)

( កាលនៅក្នុងតំណែងនេះបានធ្វើជាក្រុមប្រឹក្សាស្រុកកាយរាង ៣ ឆ្នាំផង )

- ចៅហ្វាយខេត្តកំពង់ស្វាយ (កំពង់ធំ) (១៥-១១-១៦)
- ចៅហ្វាយខេត្តកំពង់សៀម (កំពង់ចាម) (៣១-៧-១៩)
- ឧកញ៉ាមហាវិនិច្ឆ័យចាងហ្វាងសាលាឧទ្ធរណ៍ ក្រុមរដ្ឋប្បវេណី (១១-១២-២១)
- ឧកញ៉ាវិបុលរាជសេនាកូឈួយសេនាបតីក្រសួងដើងទឹកថ្នាក់ឧត្តមមន្ត្រីលេខ ២ (១៨-១០-២៣) ។

ដល់ថ្ងៃ ១៣ ខែមករាឆ្នាំ ១៩៣១ លោកបានឈប់ពីដំណែងរាជការ ដោយដល់កំណត់កាលត្រូវរីត្រែត ។

លោកឧកញ៉ានូ-កន មានគ្រឿងឥស្សរិយយស

- អល្លីយ៉ង់ហ្វ្រង់សេ (១៩០៣)
- មេដាយមាស (១៩០៩)
- មណីសារាភ័ណ៍ (១៩០៩)
- អស្សប្ញទ្ធិ (១៩១២)
- គូហ្វីស្យេប្រទេសអណ្ណាម (១៩២១)
- ធិបឌិន (កុម្មង់ឌើរ) - (១៩២៦) ។

លុះដល់មកក្នុងឆ្នាំ ១៩៤៦ ប្រទេសយើងបានបង្កើតឲ្យមានរដ្ឋសភា លោកបានចូលធ្វើជាដំណាងរាស្ត្រក្នុងគណបក្សប្រជាធិបតេយ្យ ។ កាលនៅក្នុងតំណែងនេះ, ទោះបីធ្លាក់ទៅក្នុងជរាធម៌ហើយ, លោកក៏នៅ

ស៊ូយកចិត្តទុកដាក់ ធ្វើការយ៉ាងពេញទំហឹងតាមទាំងទឹងសមត្ថភាពរបស់លោក ដរាបដល់វ័ន្តសការលាយទៅជាទីបំផុត ។ លុះមកដល់ក្នុងថ្ងៃ ៧ ៦ ៥ ឆ្នាំខាលឯកស័ក ព.ស. ២៤៩៣ (៨-២-៥០) វេលាម៉ោង ៨ យប់ លោកក៏ទទួលមរណភាពដោយពេគជរា ក្នុងកំណត់អាយុ ៧៦ ឆ្នាំនៅគេហដ្ឋានរបស់លោកក្នុងក្រុងភ្នំពេញនោះ ។

ចំពោះអក្សរសាស្ត្រ, លោកឧកញ៉ា នូ-កន ជាអ្នកនិពន្ធ ១ រូប ។ លោកមានព្យាយាមជានិច្ចក្នុងការសរសេរតែងនិពន្ធប្រែ រៀបរៀងរឿងរ៉ាវផ្សេងៗ ជាច្រើន ។ តាមដែលយើងស្រាវជ្រាវរកក្នុងពេលនេះបានឃើញ ៧ រឿងជាគតិធម៌ និងគតិលោក គឺ :

| | |
|---|---|
| - អនុសាសនី | បោះពុម្ពហើយ |
| - បកិណ្ណកកថាគោរព ៧ ប្រការ | - |
| - មហាសុបស្សីតាបស (ពាក្យកាព្យ) | - |
| - ពិម្ពា និព្វាន (ពាក្យកាព្យ) | - |
| - រឿងសាមកុក | - |
| - រឿងគុនឈិន (ផ្សាយក្នុងពតិមានកម្ពុជា) | - |
| - រឿងឥណាវ ។ | |

នូក - ពេញ

# ស្នាដៃរបស់លោកឧកញ៉ាសួ-ឥន

(ដកស្រង់ពីរឿងមហាសុបស្សីតាបស ទំព័រ ៨-៩

ថ្ងៃផុតពីដើមហេតុគ្រូពេទ្យម្នាក់ សិទ្ធិស័ក្តិពូកែពុទ្ធថ្វីដៃ
ឈ្មោះស៊ីសិទ្ធិសាតធ្មៀវថ្នាតក្រែ នៅស្រុកសុទ្ធាស្រែបុរីរម្យ ។
ចេះមើលដម្លូឈើរឹងរៃ ឈើដើមឈើដៃផាដំណាំ
ពោតឈើក្អកឈាមស្គមឈើក្រំ ឈើដំដេកផាប់ស្លាប់សព្វសាច់ ។
ឈើបុះពិសពតបួនឯង យួរស្រែងរបួសរលុះដាច់
ឆ្កួតវក់ឆ្កួតជ្រូកពេគប្រកាច់ ប៉ូសក្រែបខ្ទួបបាក់ធ្លាក់ស្បូនស្រុត ។
ដំបៅឫសបមកមរមាស់ ឈើចាស់ស្ទះខ្យល់ទល់ស្រយុត
ឈើហឹតកើតម្រេញចាញ់ឈើស្កុត អាបទុតតក្រញ៉ូលរំលមុខមាត់ ។
ឫសដូងរូងស៊ីខ្ចីប្រមុះ ឫសដុះដុះបាតធាតុពុះពោត
ក្អូនក្អាយប្រគ្រីវស្រៀវស្រៀតញាក់ លៀនលាត់អប់ផ្កាញញូញញ្ញាដើងដៃ ។
ចេះចាប់អាបព្រាយរំលាយដុំ ស្តោះផ្លុំចាប់កោសបោសបង្រែ
ទ្ធូតតឹងប្រចាប់សាច់សរសៃ បងរ៉ៃបិសាចឲ្យខ្លាចបុទ្ធិ ។
អំពើអំពាន់មន្តវិទ្យា គោបាស្នាតេះចេះស័ក្តិសិទ្ធិ
ចេះដោះចេះស្រាយក្ដាយយិត ទម្និតបិទបាំងរាំងការពារ ។
ចេះលេខអត្ថៈ ទាយឋាក់គ្រោះ ស្លាប់រស់ស្រាលធ្ងន់ស្រទន់ឈើជា
ទាយទស់មិនខុសពេលវេលា ទាយទីគ្រីហារកក្កូមិបាន ។

## ១០ – ផ្កាឈូករីក



ទៅល្អនាងរលើបរលើនយន់ ទៅល្អវង្សហានុពង្សដូចកុងលាយ

ទៅល្អឧស្គបប្រឹមញញឹមព្រាយ ទៅល្អផាយចុងសោតយានត្រយង់ ៗ

ទៅល្អយានស្រួលរៀបរកបៀបក្រ ទៅល្អកសដូចសុវណ្ណហង្ស

ទៅល្អកណ្ណដូចកលផ្កាបុស្សបុត្ត ទៅល្អវង្សវិលាស ពបរបៀបវៃ ៗ

## ជំត្រ ៣ ជាន់



កម្មអើយខុហេតុម្តេចឱអើយកម្ម សៅហ្មងមុខទុក្ខសាំមុខហ្មងសៅ

នៅឯងឯកវិវេកអង្គឯកឯងនៅ តឹងរឹងទ្រូងពេលក្តៅទ្រូងរឹងតឹង ៗ

## ១២ – ម្កុរខ្ចាក់កែវ



ស្មៀមនៅប្អូនឹកមិននៅស្មៀម រីតរឹងមុខរៀមកាក់រឹងរីត

គិតម្តងចង់កាត់ នឹកម្តងគិត បានម្តេចចូលជិតធ្វើម្តេចបាន ៗ

## ១៣ – សិង្ហតោ លេងកន្ទុយ



ទឹងប្រឹងទៅប្រលោមល្ងួងដួងជីវិត ក្រែងមិនមិត្តជិតការពារអឹអឹង

ប្អូនឹងថែងតែងការសារមិនដឹង ក្រែងព្រលឹងវឹងវាត់អធ្យាស្រ័យ ៗ

## ១៤– វលកខ្ទប់ប្រាំង



សត្វទាំងឡាយសាយទាំងលោកសឹងសោកសៅ មួយជាប់នៅម៉ៅជានិច្ច

គិតកងលោក

វះមិនផុតតែមិនផុនបុនព្រោះពេក រកប្រយោជន៍រួចប្រយោគគោកគំនិត ។

## ១៥– វលក យោលយារ



ពុកកំរែតបិត្តកំរើររំពឹងឈ្វេង ទុកម្មព្រងបង្វែងព្រាត់ឲ្យព្រាត់គ្នា

មិនទាន់បានប្រាណមកមកពីអគ្គា កើតវេរវឿងជាពេកមិនយោគស្មាន ។

## ១៦ – យតិភង្គ



សង្ស្រាអើយបង បងភ្ញាប់ផ្ញាប់ចិត្តតោម- ឆ្ងាយមិនឲ្យឲ្យទោមនស្ស-

ស្ងៀសចិត្តហៅហៅនៅកើតកម- ភ្លលប្រកបកបអគ្គាគួរស្នេ-(ហា) ។

## ១៧ – សបាត់សបឹង



ដឹងជាគេអន់គាក់មិនស្ម័គ្រមិនស្មោះ មកប្រឹងថែរថៃស្រណោះគាណោះ

គាល័យ ។

ចាប់ស្រឡាញ់ពេញកន្ទេនសង្រែនសង្រៃ ឲ្យស្រមៃហាក់ថ្ងៃដល់គល់

កោញ ៗ

បណ្ណាល័យជាតិ

## ១៨ – ត្រីពិធពន្ធ



តែយប់ដេកប៉ូលដេកដេកមិនលក់ ដូចគេកក់កក់កក់កិលកៃ

ហាមមិនទឹងទឹងកាត់ទឹងកែវៃ នៅសង្ស័យនិស្ស័យសែចិត្តា ៗ

## ១៩ – នាគរាជប្លែងឫទ្ធិ



មិត្តសង្កាចាំពាក្យទៀនបំពោះ ទោះដំពាក់នេះនោះគួរអាណិត

គិតអនាថនឹកខ្វះបំណាច់គិត តែបំណាងប៉ង់ស្និទ្ធជាគូគាប់ ៗ

## ២០ – នាគបរិព័ន្ធ



ប្រជិតកើយខ្មើយនួមរួមមណ្ឌល រួមមណ្ឌលទិមលនិមិត្តហាយ

នៃមិត្តមាសពាសរង្សទ្រង់គោមតាយ ទ្រង់គោមចើតឲ្យកើតកាយគួរកម្សោ ៗ

## ២១ – គោព័ន្ធស្មឹង



សង្ស័យចិត្តកន្និដ្ឋាយ៉ាងណាអេះ អេះមកប្រែប្រួលច្រេះខុសនិស្ស័យ

និស្ស័យដើមធ្លើមបេះមកសព្វថ្ងៃ. ថ្ងៃនេះតើមាសថ្លៃគិតយ៉ាងណា ៗ (មាឆ៣)

## ការសាងអាយតនៈ (ខេមកគំអប់)

របស់នេះគួរប្រើប្រាស់បាន ឬប្រើប្រាស់មិនបាន មានរបស់ខ្លះទៀត មិនមានក្លិនអ្វីជាគ្រឿងសំគាល់ឡើយ បើមិនមានធម្មជាតិដទៃដែលមានក្លិនមកជាអាស្រ័យផង នោះប្រមុះនឹងស្រង់យកក្លិនអំពីរបស់នោះមិនបានឡើយ ប៉ុន្តែការហាត់រៀនស្រង់យកក្លិននេះមិនទាន់មានអ្នកប្រាជ្ញណាអាចចាត់ចែងវិទ្យាសាស្ត្រ សំរាប់បង្ហាត់បង្រៀន សិក្សាតាមកុលបុត្រទាំងឡាយឲ្យមានវិជ្ជានេះនៅឡើយទេ ៗ ច្រើនតែចេះសំគាល់តាមគ្នា អំពីគ្រូសាខ្លះ អំពីអ្នកដទៃខ្លះ ហេតុនេះប្រមុះ បើអ្នកណាមួយបានហាត់ឲ្យស្ទាត់ជំនាញ ក្នុងវិធីស្រង់យកក្លិននេះពិតប្រាកដហើយ នឹងអាចទទួលយកផលប្រយោជន៍ អំពីវិជ្ជានេះបាន ហៅថាប្រមុះមានសំណាង ៗ

មួយទៀត សូមបញ្ជាក់ថា ការទទួលផលប្រយោជន៍ អំពីប្រមុះនេះ លុះណាតែអ្នកពិចារណាដេញដោលរកហេតុផលក្នុងរឿងនេះ ឲ្យឃើញជាក់ច្បាស់ទើបអាចចូលចិត្តបាន ព្រោះមិនមានក្បួនតម្រាណាមួយសំដែងឲ្យឃើញជាក់ស្តែងអំពីផលទាំងឡាយ ដែលប្រមុះអាចស្វែងរកបានមកប្រគល់ឲ្យនរជនប្រុសស្រី ដែលកើតឡើងក្នុងលោកសន្និវាសនេះទេ ៗ យើងគ្រាន់តែបង្ហើបសេចក្តីប៉ុណ្ណោះ ជាគ្រឿងពិចារណានៃវិញ្ញូជនទាំងឡាយ ទុកជាគោលការណ៍សំរាប់រិះរកឲ្យបានតទៅ ៗ

បើនិយាយតាមផ្លូវពុទ្ធសាសនាវិញ ប្រមុះនេះ មានកិច្ចការយ៉ាងសំខាន់ណាស់ គឺជាគោលនៃការចំរើនអនាបានស្សតិកម្មដ្ឋាន កំណត់ខ្យល់ចេញចូល ដែលជាគ្រឿងធ្វើទឹកចិត្តឲ្យផុតចាកនីវរណធម៌ គឺ: ឧទ្ធច្ច, កុក្កុច្ច, ថីនមិទ្ធ, និងវិចិកិច្ឆា ដែលជាឫសគល់នៃអកុសលយ៉ាងគ្រោតគ្រាត ។

## សាងអណ្ដាត

ស. — អណ្ដាត គេត្រូវសាងដូចម្ដេច?

ឆ. — អណ្ដាត គេត្រូវកសាង ដោយការហាត់រៀន · ទន្ទេញឲ្យចេះចាំក្បួនច្បាប់ទាំងឡាយ រួចហើយត្រូវហាត់រៀននិយាយឲ្យប្រកបដោយលក្ខណ: ៤ យ៉ាង:

១ — រៀនពោលពាក្យឲ្យដឹងឋានៈនៃបុគ្គលដែលយើងត្រូវនិយាយដូចជា ចំពោះព្រះមហាក្សត្រិយ៍, ចំពោះរដ្ឋមន្ត្រី, ចំពោះភ្នាក់ងាររាជការទាំងឡាយជាលំដាប់មក, ចំពោះព្រះសង្ឃ, ចំពោះចាស់ព្រឹទ្ធាចារ្យ, ចំពោះមាតា-បិតា, ចំពោះបង-ប្អូន, សាច់សាលោហិត, ចំពោះ-ញាតិមិត្ត និងចំពោះជនសាមញ្ញទូទៅ ។

២ — មុននឹងនិយាយ ត្រូវស្ទង់មើលការៈចិត្តរបស់អ្នកស្ដាប់ថាមនុស្សបែបនេះចូលចិត្តនឹងសំដីរបៀបនេះ មនុស្សបែបនោះចូលចិត្តនឹងសំដីរបៀបនោះ បើនិយាយដូច្នេះ នឹងកើតជាគុណ និយាយដូច្នោះ នឹងកើតជាទោស និយាយរបៀបនេះ ត្រូវចិត្តបុគ្គលពួកនេះ ខុសចិត្តបុគ្គលពួកនោះៗ

៣ – ត្រូវឲ្យដឹងច្បាស់នូវទីបំផុតនៃសំដីរបស់ខ្លួនថា សំដីរបស់អញមានទីបំផុតបីយ៉ាង គឺទីបំផុតខាងដើម ១ ទីបំផុតត្រង់កណ្តាល ១ ទីបំផុតខាងចុង ១ ៗ ព្រោះសំដីខ្លះយើងពោលទៅហើយ ឲ្យទោសខាងដើម ឲ្យគុណត្រង់កណ្តាលនឹងខាងចុង, សំដីខ្លះឲ្យទោសត្រង់កណ្តាល ឲ្យគុណត្រង់ខាងដើមនឹងខាងចុង សំដីខ្លះទៀតឲ្យគុណខាងចុង ឲ្យទោសត្រង់ខាងដើមនឹងកណ្តាល មកអំពីសំដីទាំងឡាយ ដែលយើងនិយាយចំពោះបុគ្គលណាមួយក្តី ចំពោះអ្នកទាំងឡាយដទៃក្តី រមែងមានការប្រឆាំងឬការសម្រួលតាមកិច្ចការឬទឹកចិត្ត របស់អ្នកស្តាប់ដែលហេតុនាំឲ្យកើតជាគុណឬជាទោស ៗ ហេតុដូច្នេះមុននឹងនិយាយចំពោះបុគ្គលឬទីប្រជុំណាមួយ ត្រូវគិតរកទីបំផុតនៃសំដីរបស់ខ្លួនសិនថា: សំដីរបស់ខ្លួននេះ នឹងទៅជាគុណ ឬទៅជាទោសដល់ខ្លួនជាអ្នកនិយាយឬដល់បុគ្គលជាអ្នកស្តាប់ ៗ

៤ – មានសំដីខ្លះ និយាយទៅហើយ នាំឲ្យខូចប្រយោជន៍របស់ខ្លួនផង របស់អ្នកដទៃផង, សំដីខ្លះ និយាយទៅហើយនាំឲ្យចំរើនប្រយោជន៍របស់ខ្លួនផង របស់អ្នកដទៃផង, សំដីខ្លះនិយាយទៅហើយ នាំឲ្យចំរើនប្រយោជន៍របស់អ្នកដទៃ ខូចប្រយោជន៍របស់ខ្លួន សំដីខ្លះទៀត និយាយទៅហើយ នាំឲ្យចំរើនប្រយោជន៍របស់ខ្លួន ខូចប្រយោជន៍របស់អ្នកដទៃ ៗ ដូច្នេះមុននឹងនិយាយ ត្រូវគិតថា សំដីនេះ គាប់ធ្វើឲ្យ

ចំរើនឬឲ្យវិនាសប្រយោជន៍របស់ខ្លួន ឬ របស់អ្នកដទៃ ដែលជាហេតុនាំឲ្យកើតទៅជាគុណ ឬ ទៅជាទោស ។ កាលបើគិតឃើញហេតុផលដូច្នេះច្បាស់ប្រាកដហើយ ត្រូវមានកិច្ច ២ យ៉ាង គឺមួយយ៉ាងត្រូវស្ងៀមដូចពាក្យបុរាណថា “ អឹមជាជាងអៀម ស្ងៀមជាជាងស្រដី ” មួយយ៉ាងទៀត ត្រូវតែនិយាយដោយមធ្យោបាយណាមួយ ដូចពាក្យបុរាណថា “ បើស៊ិនជានិយាយកុំខ្លាចទាល់ បើស៊ិនជាក្អាលកុំខ្លាចបាញ់ ” ។

សំដីនេះ អ្នកប្រាជ្ញទាំងឡាយលោកទុកជាជារបស់ឯកនៅក្នុងលោក ព្រោះថាជាពន្លឺនៃកិច្ចការទាំងឡាយផង ជាមូលដ្ឋាននៃវិទ្យាសាស្ត្រទាំង-ឡាយផង ដូច្នេះ បានជាលោកកំណត់សំដីជាពីរផ្នែក គឺ ១ ផ្នែកឲ្យជាប់នៅនឹងផែនចារឹកទាំងឡាយមានក្រដាស, ស្លឹករឹត, លោហជាតិ និងថ្មជាដើម ដែលហៅថាអក្សរសាស្ត្រ ជាសំដីសំរាប់ញុំាងចក្ខុបសាទនឹងសោតប្បសាទនៃនរជនទាំងឡាយ ឲ្យតាំងរិះរកការពិចារណាចំពោះហេតុផល ដែលចេញអំពីគំនិតរបស់អ្នកវិទ្យាសាស្ត្រទាំងឡាយ ហើយជាសំដីអាចតាំងនៅក្នុងចិរកាលចំពោះកិច្ចការទាំងឡាយ ឬ ចំពោះកិច្ចកលឧបាយទាំងឡាយ នៃអ្នកដែលប្រព្រឹត្តអំពើផ្សេងៗ ដែលគួរយកជាគតិវិនិច្ឆ័យរបស់អ្នកវិទ្យាសាស្ត្រ ធម្មសាស្ត្រ ភូមិសាស្ត្រ បវត្តិសាស្ត្រ គណិតសាស្ត្រទាំងឡាយជាដើម តាមដំណើរធម្មៈគ្រប់ប្រភេទដែលតាំងនៅក្នុងខន្ធសន្តាននៃសត្វលោក ។

មួយផ្នែកទៀត សំដីដែលគេគ្រាន់តែនិយាយដោយកាទទេៗ ដើម្បីជាទីសណ្ដាប់នៃជនដទៃ ក៏មានសារៈសំខាន់ដូចគ្នាដែរ ។

ម្យ៉ាងទៀតសំដីនេះ លោកអ្នកប្រាជ្ញទាំងឡាយបានចែងជាសុភាសិតទុកមកថា: “សំដីជាឯក លេខជាទោ” ជាដើម ។

សំដីនេះចែកចេញជា ២ គឺសំដីល្អ ១ សំដីអាក្រក់ ១ ។ សំដីល្អបានដល់ពាក្យពោលប្រកបដោយប្រយោជន៍បច្ចុប្បន្ន នឹងបរលោក ដោយវៀរចាកវចីទុច្ចរិត ៤ ។ សំដីអាក្រក់បានដល់ពាក្យពោលបំផ្លិចបំផ្លាញប្រយោជន៍ទាំង ២ ដោយវៀរចាកវចីសុចរិត ៤ ។ ហេតុនេះ លោកអ្នកប្រាជ្ញទាំងឡាយ កំណត់សំដីនេះទុកថាជាអាវុធ ១ យ៉ាង សំខាន់បំផុតសំរាប់មនុស្សលោក ។

ដូចម្ដេច ដែលហៅថា “សំដី”? សំដីនេះបានដល់សូរស័ព្ទដែលលាន់ឮចេញរំពងអំពីមាត់នៃមនុស្សប្រុសស្រីទាំងឡាយ ដោយបរិយាយលក្ខណៈ ឬដោយចែលក្ខណៈ ។

ដូច្នេះ ជនប្រុសស្រីទាំងឡាយ គប្បីកសាងសំដីនេះ ឲ្យបានម៉ត់ចត់ល្អ ក្នុងវិធីសាកសួរ, ដោះស្រាយ, ថ្លែងបរិយាយ ឬ ជជែកគក់ ដោយលក្ខណៈដូចបានពោលហើយខាងលើ ទើបហៅថា “អណ្ដាតមានសំណាង” ។

តែ - ផុន

១៨១ – អ្នកណា ចង់បានស្ត្រី ត្រូវចូលទៅធ្វើស្និទ្ធយ៉ាងជិត សេពគប់បន្តិចម្តងៗ នេះជាផ្លូវ ឲ្យស្ត្រីគាត់ ចង់បានអ្នកនោះវិញ ។

១៨២ – ស្ត្រីគាត់ដែលធ្លាប់ប្រព្រឹត្តកន្លងប្រវេណី (ឥតមារយាទ, ខិលខូច) អាចបិតទៅ (បរិសុទ្ធ, មានមារយាទ) មិនកន្លងប្រវេណី គ្រប់កាលទាំងពួងបាន ព្រោះតែមិនមានប្រុសចង់បានផង ព្រោះតែខ្លាចអ្នកនៅជុំវិញផង ។

១៨៣ – ប្រុសណា ដែលស្ត្រីមិនគប្បីចូលទៅជិត មិនមានទេ ស្ថិតនៃអាយុប្រុស សំរាប់ស្ត្រីគាត់ទាំងឡាយ ក៏មិនមានកំណត់ដែរ ឲ្យឈ្មោះតែប្រុស ទោះរូបអាក្រក់ឬរូបល្អ ស្ត្រីគាត់តែងតែព្រាក់ព្រមស្ម័គ្រទាំងអស់ ។

១៨៤ – ប្រុសណាដែលស្រឡាញ់ស្ត្រី ស្ត្រីនេះតែងទួលកែកាយស្ម័គ្រគប់ទាំងអស់ ដូចជាសំពត់សាដកដែលគេប្រើលាក់លៀម ទោះរិចរិលជាប់ប្រគោងតែដោយជាយ ហើយធ្លាក់ចុះពីចង្កេះក៏ដោយ គង់តែគេនៅប្រើប្រាស់ ។

១៨៥ – ល័ក្តក្រហម ទាល់តែគេឈ្លីប្របាច់ទើបចេញក្រហមយ៉ាងណា ប្រុសទាល់តែស្ត្រីឲ្យដៃទើបស្រឡាញ់យ៉ាងនោះដែរ ប្រុសដែលស្រឡាញ់ស្ត្រីហើយ តែងធ្លាក់ចុះទៀបបាទមូលនៃស្ត្រីទាំងឡាយទាំងអំណាច ។

ព្រះរាជាទ្រង់ព្រះតម្រិះពិចារណាឃើញប្រការយ៉ាងនេះហើយ ទើបទ្រង់បោះបង់ទន្តិលៈចោលលែងប្រោសប្រាណតាំងពីកាលនោះមក គឺទ្រង់ឃាត់ហាមទន្តិលៈ លែងឲ្យចូលគាល់ហៅដល់ព្រះរាជនិវេសន៍ដូចប្រក្រតីដើមទៀត ។ គ្រានោះ ទន្តិលៈកាលឃើញថាព្រះរាជាបោះបង់ខ្លួនចោលលែងប្រោសប្រាណដូច្នេះហើយ ក៏គិតថា :–

១៤៦– នរជនណា ដែលបានមានទ្រព្យសម្បត្តិហើយមិនឡើងចាង? នរជនណា ជាវិស័យមនុស្ស ដែលផុតលែងសេចក្តីទុក្ខ? នៅលើផែនដីនេះ, នរជនណា ដែលស្រីមិនធ្វើឲ្យឈឺចិត្ត? នរជនឈ្មោះណាហ្ន៎ ជាទីស្រឡាញ់នៃព្រះរាជា? នរជនណា ដែលមិនចូលទៅកាន់ទីគោចរនៃសេចក្តីស្លាប់? នរជនណា ជាយាចក ហើយគេគោរពកោតក្រែង? នរជនណា ដែលធ្លាក់ទៅក្នុងសំណាញ់នៃទុជ៌ន ហើយបានសេចក្តីក្សេមក្សាន្ត? ។

១៤៧– សេចក្តីបរិសុទ្ធិក្នុងសត្វក្អែក, ពាក្យសច្ចៈក្នុងពួកអ្នកល្បែង, សន្តិភាពក្នុងសត្វពស់, ការស្ងប់កាមគុណក្នុងពួកស្ត្រីទាំងឡាយ, សេចក្តីក្លាហានក្នុងមនុស្សកំឡាច, ចិត្តស្ងប់ស្ងាត់ក្នុងមនុស្សប្រមឹក និងព្រះរាជាជាមិត្ត នរជនណា ដែលបានឃើញ ឬក៏ដែលបានឮដូចសេចក្តីខាងលើនេះទេ? ។

ម្យ៉ាងទៀត, ក្នុងរាជសម្ព័ន្ធនេះ អាត្មាអញមិនដែលធ្វើអាក្រក់ចំពោះព្រះរាជា ឬជនដទៃណាមួយសោះ ចុះរឿងអាត្មាអញនេះកើត

មកពីហេតុអ្វី ? ។ ឯគោរម្ភៈជាអ្នកបោស កាលឃើញគេឃាត់ហាមមិនឲ្យទន្តិលៈចូលទៅកាន់ព្រះរាជវាំងយ៉ាងនេះហើយ សប្បាយចិត្តសើចក្អាកក្អាយ ក៏និយាយឡកឡឺយទៅកាន់ទ្វារបាលទាំងឡាយថា: "នែទ្វារបាលទាំងឡាយ ! ទន្តិលៈនេះព្រះរាជាទ្រង់ប្រោសប្រាណ ហើយតាំងឲ្យនៅក្នុងដំណែងដ៏ខ្ពស់ ជាអ្នកដាក់ទោសទណ្ឌកម្ម និងអនុគ្រោះគ្រាប្រណីព្រមទាំងសម្រេចការខ្លួនឯង ឥឡូវនេះ ក៏ត្រូវព្រះរាជាឃាត់ហាមមិនឲ្យចូលវាំងហើយ ដូច្នេះ ក្នុងការឃាត់ហាមមិនឲ្យវាចូល អ្នកទាំងឡាយត្រូវយកចំពាមដៃច្បាមកវាបណ្ដេញចេញទៅ ធ្វើឲ្យដូចជាកាលវាធ្វើរូបខ្ញុំដូច្នោះដែរ" ។ ទន្តិលៈឮសំដីគោរម្ភៈដូច្នោះហើយ ក៏គិតពិចារណាថា: "ឱ រឿងនេះ ដើមហេតុមកពីតាគោរម្ភៈនេះឯងទេតើ ! ព្រោះថា :–

១៤៨ – ក្នុងលោកនេះ, នរជនណា ទោះជាអ្នកត្រកូលទាបថោកក្ដី ជាអ្នកល្ងង់ខ្លៅក្ដី ជាអ្នកគេមើលងាយក្ដី បើបានចូលទៅផ្គាប់ផ្គុនព្រះភូមិបាលហើយ នរជននោះ ត្រូវគេបូជាក្នុងទីទាំងពួង ។

១៤៩ – មនុស្សត្រម៉ែកក្ដី ឬជាមនុស្សកំឡាចក្ដី បើបានជារាជសេវកាមាត្យ តែងបានផលអំពីបណ្ដាជន ឯចំណែកសម្បាច់ជាផលនៃមនុស្សនោះមិនមែនធ្វើឲ្យទៅជាបុគ្គលមានគុណទេ ។

សេដ្ឋីទន្ទិលៈ អៀនអន់ខ្មាស់ណាស់ មុខស្រពោនស្រៀមក្រំក្នុងចិត្ត ព្រោះសាបរលាបអំណាចយសសក្ដិសិរីសួស្ដី ក៏ដើរត្រឡប់ទៅគេហដ្ឋានខ្លួនវិញដោយតូចចិត្ត ។ ពេលល្ងាច គាត់ហៅគោរម្ភៈមកកាន់ផ្ទះខ្លួន ហើយឲ្យសំពត់មួយគូ ទើបនិយាយលួងលោមថាៈ “ នែសំឡាញ់ដ៏ចំរើន ! ខ្ញុំឃើញសំឡាញ់ចូលទៅអង្គុយជិតព្រះរាជ-អាសនៈ ជាកន្លែងមិនសមគួរដល់សំឡាញ់ឯង ខ្ញុំស្ដីបន្ទោសកំហែងប្រមាថមើលងាយហើយបណ្ដេញសំឡាញ់កាលនោះ មិនមែនជាខ្ញុំស្អប់ខ្ពើមទេ ” ។ គោរម្ភៈ កាលទន្ទិលៈឲ្យសំពត់មួយគូហើយនិយាយចាក់បេកចាក់ស្ដរស្ទួចិត្តឲ្យស្រួល ក៏អរកខ្ទឹបកខ្ទុបប្រៀបដូចជាបានរាជសម្បត្តិក្នុងឋានសួគ៌ រីករាយសប្បាយចិត្តណាស់ ឆ្លើយតបទៅវិញថាៈ “ លោកសេដ្ឋី ! ខ្ញុំបាទបាត់ខឹងនឹងលោកហើយ សូមលោកកុំព្រួយបារម្ភអ្វី លោកចាំមើលប្រាជ្ញាខ្ញុំ មិនយូរប៉ុន្មានទេ ខ្ញុំនឹងដឹកនាំឲ្យព្រះរាជាប្រោសប្រាណលោកឲ្យដូចដើមវិញ ” គោរម្ភៈនិយាយមកដូច្នេះហើយ ក៏លាសេដ្ឋីដើរចេញទៅដោយក្ដីរីករាយដ៏ក្រៃលែងព្រោះថាៈ

១៥០ – នុហ្ន៎ ចារិតជនដញ្ញឹងនឹងមនុស្សវិលខ្លួចដូចគ្នាណាស់តើ ! រាបះឡើងខ្ពស់ដោយរបស់បន្តិច រាធ្លាក់ចុះទៅទាបដោយរបស់បន្តិច ។

តមកថ្ងៃមួយ, កាលព្រះរាជាទ្រង់កំពុងស្ដេចរៀបនិទ្រា, គោរម្ភៈចូលទៅក្នុងប្រាសាទត្រង់កន្លែងដែលនោះទៀត, បោសបណ្ដើរនិយាយ

អើម្នាក់ឯងបណ្ដើរថា: យីអើហ៎! ព្រះករុណាស្ដេចទ្រង់ឥតពិចារណា ស្ដេចទ្រង់បន្ទោបង់បណ្ដើរទ្រង់សោយផ្លែត្រសក់បណ្ដើរ" ។ ព្រះរាជា លុះទ្រង់ព្រះសណ្ដាប់ពាក្យគោរម្ភៈនិយាយដូច្នោះហើយ ទ្រង់មានសេចក្ដីសង្ស័យខ្វល់ក្នុងព្រះទ័យ ទើបទ្រង់ត្រាស់សួរទៅគាមថា: "នែអាគោរម្ភៈចង្រៃ! អាឯងហ៊ាននិយាយពាក្យរើរាយអ្វីឬកម៉្លេះ? អញមិនសម្លាប់អាឯងចោលបង់សៀត ព្រោះអញយល់ថាអាឯងធ្វើការក្នុងព្រះរាជដំណាក់អញ, ចុះអាឯងឃើញអញធ្វើអំពើបែបនេះពីកាលណា ?" ។ គោរម្ភៈក្រាបទូលថា: "បពិត្រព្រះទេពវង្ស! សូមទ្រង់ព្រះករុណាអភ័យទោស ទូលព្រះបង្គំជាខ្ញុំជាប់ចិត្តនឹងល្បែង នៅរាល់ព្រឹក មិនបានទទួលព្រះរាជ-ទានដំណេកសោះ ទូលព្រះបង្គំជាខ្ញុំកំពុងងោក ក៏ស្រាប់ងោកងក់លក់មិនដឹងខ្លួន ពាក្យដែលទូលព្រះបង្គំជាខ្ញុំនិយាយហើយ ទ្រង់បានព្រះសណ្ដាប់នោះ ទូលព្រះបង្គំជាខ្ញុំនិយាយរើរាយមិនដឹងខ្លួនទេ សូមទ្រង់ព្រះករុណាថ្លៃវិសេសមេត្តាប្រោសអភ័យទោស ព្រោះទូលព្រះបង្គំជាខ្ញុំលុះក្នុងអំណាចនៃសេចក្ដីងោកងក់" ។ ព្រះរាជា កាលទ្រង់បានព្រះសណ្ដាប់ពាក្យគោរម្ភៈហើយ ទ្រង់ព្រះតំរិះថា: "ក្នុងមួយជីវិតអាត្មាអញនេះ អាត្មាអញមិនដែលចូលទៅបន្ទោបង់ ហើយស៊ីផ្លែត្រសក់ដល់ម្ដងសោះ, ដំណើរនេះ អាគោរម្ភៈវានិយាយតែផ្ដាសពីអាត្មាអញទៅទេ យ៉ាងណាមិញ ឯទន្ដិលៈក៏អាចង្រៃនេះវានិយាយផ្ដេសផ្ដាស

ដូច្នេះយ៉ាងនេះដែរ បើដូច្នោះ អំពើដែលអាត្មាអញបោះបង់ចោលលែងរាប់អានទន្តិលៈ កំសត់កម្រនេះជាអំពើមិនសមគួរទេ, មនុស្សប្រាកដដូចទន្តិលៈនេះបុគ្គលមិនគួរធ្វើបាបគ្នាទេ, តាំងពីអាត្មាអញបោះបង់គ្នាចោលទៅ កិច្ចការក្នុងព្រះរាជដំណាក់ក្តី កិច្ចការក្នុងព្រះនគរក្តី ខ្ជីខ្ជារយើករយោកឥតសណ្តាប់ធ្នាប់ខ្លាំងណាស់ ។ លុះទ្រង់ពិចារណាមើលសព្វគ្រប់ហើយ ព្រះរាជាទ្រង់ត្រាស់បង្គាប់ឲ្យហៅទន្តិលៈ មកកាន់ព្រះរាជ-និវេសន៍វិញ ទ្រង់ដោះសង្វាចេញពីព្រះស្កន្ធប្រទាន ព្រមទាំងសំពត់អាវគ្រឿងប្រដាប់ទាំងឡាយ ហើយតាំងជាអធិការធំផ្តាច់ក្នុងព្រះនគរ ។ ចចកទមនកៈនិយាយមកដល់ត្រង់នេះ ទើបនិយាយបញ្ជាក់ប្រាប់គោ-សញ្ជីវកៈថាៈ “ព្រោះហេតុនេះបានជាខ្ញុំពោលថាៈ “នរជនណា មិនគោរពជនឧត្តម ដូច្នេះជាដើម” (លេខ ១៣០) ។

(មានត)

---

# កែតម្រូវ

ក្នុងសៀវភៅលេខ ៩ ទំព័រ ៣២៧ បន្ទាត់ ៤-៥ ត្រង់ពាក្យថា “... មូលហេតុជាបាប គឺ អលោភៈ អទោសៈ អមោហៈ” កែជា ‘... មូលហេតុជាបាប គឺ លោភៈ ទោសៈ មោហៈ” ។

សៀវភៅលេខ ១០ ទំព័រ ៣៧៣ បន្ទាត់ ១១ “ជាកដត្តា” កែថា “ជាកត្តា” ។ ទំព័រ ៣៨៨ បន្ទាត់ក្រោមបង្អស់ “ធ្ងន់ល្អងជាស្តេច...” កែជា “ទូនល្អង...” ។

# សេចក្តីថ្លែងការណ៍គណៈកម្មាធិការ

ទស្សនាវដ្តី "មិត្តសាលាបាឡី" បានរស់រានមានអាយុចំនួន ១១ ខែមកហើយ តាំងពីបានខំប្រឹងប្រែងផ្ចាញ់ឧបសគ្គជាច្រើនប្រការ ឧបសគ្គចំពូកទី ១ មកពីការចាប់ផ្តើមបណ្ណាះបណ្តាលទស្សនាវដ្តីនេះឡើងក្នុងខែទី ២ នៃឆ្នាំ ១៩៥០ ទៅហើយ ឧបសគ្គចំពូកទី ២ មកពីពេលត្រូវមានកិច្ចការរវល់ច្រើន ពុំបានរៀបអក្សរឲ្យដោយឆាប់រួសរាន់ទាន់ចិត្ត ទើបទស្សនាវដ្តីរបស់យើងនេះចេញពុំទាន់ពេលវេលា ធ្វើឲ្យអ្នកអានរង់ចាំយូរបន្តិច ទំរាំទើបបានមួយលេខៗយកទៅអាន ជាហេតុនាំឲ្យអស់លោកអ្នកខ្លះបញ្ចេញសេចក្តីត្អូញត្អែរឿយៗ ពីការយឺតយូរនេះ យើងនឹកស្មានថា បើអស់លោកអ្នកបានជ្រាបនូវហេតុដែលនាំឲ្យកើតសភាវការណ៍បែបនោះដោយសព្វគ្រប់ហើយ គង់នឹងឲ្យនូវសេចក្តីអភ័យដល់យើងដោយពិត ព្រោះហេតុទាំងនោះ ពុំមែនជាប់ទាក់ទងដោយចេតនារបស់យើងទេ ។

ឧបសគ្គចំពូកទី ៣ គឺមកពីអស់លោកអ្នកជាខ្លះ បានចុះឈ្មោះប្រចាំឆ្នាំ ឬប្រចាំឆមាសហើយ ពុំបានបង់ថ្លៃជាមុន ជាហេតុនាំឲ្យលំបាកដល់ការប្រមូលថ្លៃបោះពុម្ពទៅយកទស្សនាវដ្តីមួយលេខៗ ។ ហើយជាហេតុឲ្យមានសេចក្តីបារម្ភព្រួយឥតអាក់ ក្រែងទស្សនាវដ្តីនេះនឹងធ្លាក់ក្នុងជោគនៃទស្សនាវដ្តីខ្លះ ដែលផុតជីវិតរលត់បង់ទៅ ព្រោះរកថ្លៃឲ្យពេង-ពុម្ពពុំបាន តែសេចក្តីបារម្ភព្រួយនោះ បានអន្តរធានទៅហើយ ទើប

ទស្សនាវដ្ដីនេះអាចគង់ទ្រង់មកដល់លេខនេះ ទាំងនេះដោយសារតែអស់លោកអ្នកអានទាំងឡាយ មានសេចក្ដីពេញចិត្តដ៏មោះមុតចំពោះព្រះពុទ្ធសាសនានិងអក្សរសាស្ត្រ បានខ្នះខ្នែងជួយឧបត្ថម្ភគាំទ្រមិនឲ្យវិនាសសាបសូន្យទៅ តាមដែលអាចនឹងប្រឹងប្រែងបានមកហើយ យើងសូមឆក់យកឱកាសនេះ ដើម្បីសំដែងសេចក្ដីអំណរគុណ ចំពោះអស់លោកអ្នកអានទាំងឡាយក្នុងទីនេះផង ។

តែថានៅមួយខទៀត ទស្សនាវដ្ដីមិត្តសាលាបាលី នឹងរួបរួម បានអាយុជីវិតមួយឆ្នាំហើយ នឹងត្រូវបន្តអាយុជីវិតឲ្យបានចំរើន ក្នុងឆ្នាំមុខតទៅទៀត ដែលនឹងចំរើនលូតលាស់ទៅបាន ក៏អាស្រ័យអស់លោកអ្នកអានទៀត ដូច្នេះសូមលោកអ្នកអានទាំងឡាយកុំភ្លេចនឹងបំរុងខ្លួនចាំចុះឈ្មោះជាវតទៅ ដោយមេត្តាបង់ថ្លៃជាវជាមុន ដើម្បីឲ្យងាយដល់ការចាត់ចែងខាងពេងពុម្ព ។

**សូមលោកអ្នកអានទាំងឡាយកុំភ្លេចចុះឈ្មោះជាវទស្សនាវដ្ដី មិត្តសាលាបាលី សំរាប់ឆ្នាំ ១៩៥១ និងបបួលញាតិមិត្តឲ្យស្ម័គ្រចិត្តចុះឈ្មោះជាវ !**

**ដម្លៃជាវប្រចាំឆ្នាំ ១០០ រៀល !**

IMPRIMERIE ROYALE